# 11 ការកែប្រែដី និងការដាំដើមឈើឡើងវិញ

នៅក្នុងជំពូកនេះ : ទំព័រ


ការបង្ការសំណឹកដី . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 200

សាច់រឿង : បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល រៀនសូត្រពីកសិករ . . . . . . . . . . . . . 201

ការកែប្រែដីដែលខូចខាតឡើងវិញ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 202

ការលូតលាស់ឡើងវិញតាមធម្មជាតិ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 202

វិធីធ្វើជុំគ្រាប់ពូជ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 204

សាច់រឿង : ការជួយដើមឈើឲ្យលូតលាស់ដោយខ្លួនឯង . . . . . . . . . . . . . . . . . . . . 205

ការដាំដើមឈើ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 206

ការបណ្ដុះឈើនៅមណ្ឌលបណ្ដុះកូនឈើ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 209

ការកែប្រែផ្លូវទឹកនិងដីល្បាយខ្សាច់ឡើងវិញ . . . . . . . . . . . . . . . . . . . . . . . . . . . . .214

# ការកែប្រែដី និងការដាំដើមឈើឡើងវិញ



សហគមន៍មួយមានសុខភាពល្អ គឺអាស្រ័យលើការផ្គត់ផ្គង់ទឹកស្អាតយ៉ាងទៀងទាត់, ដីមានជីជាតិ, និងជាទូទៅគឺអាស្រ័យលើដើមឈើ និងធនធានដែលពួកគេបានការពារ។ ដើម្បីថែទាំនិងកែលម្អសុខភាពសហគមន៍ ជាការសំខាន់គឺត្រូវស្វែងយល់ពីវិធីកែប្រែដីឡើងវិញ និងពីវិធីប្រើប្រាស់ដីក្នុងវិធីស្ថិរភាព។ នៅពេលដីត្រូវបានបំផ្លាញ, ដើមឈើបានកាប់រំលំ, ដីបានបាត់បង់ដោយសារសំណឹកពីខ្យល់និងទឹក, ក៏នៅមានវិធីជាច្រើនដែលអាចធ្វើឲ្យដីមានសុខភាពប្រសើរនិងមានផលិតភាពឡើងវិញបាន។

# ការបង្ការសំណឹកដី

ការបាត់បង់ដី ឬហៅថាសំណឹកដី គឺបង្កឡើងដោយសារខ្យល់និងទឹកដែលហូរនាំដីទៅជាមួយ។ ការការពារដីពីសំណឹក ជាពិសេសនៅជាយភ្នំចោតៗ ធ្វើឲ្យដីកាន់តែមានសមត្ថភាពក្នុងការដាំដំណាំ, ការពារប្រភពទឹកនៅជើងភ្នំ, និងបង្ការការបាក់ដី។ កសិករអនុវត្តតាមគោលការណ៍បីយ៉ាងដើម្បីបង្ការសំណឹកដី និងទឹកហូរហៀរលើដី :

១. **ពន្យឺតលំហូរទឹក** តាមរយៈការបង្កើតរបាំងធម្មជាតិពីលើទីជម្រាលមកដល់ក្រោម។

២. **បំបែកផ្លូវទឹក** តាមរយៈការជីកព្រែកដើម្បីបំបែកទឹក ឬបង្វែរទឹកទៅទីណាមួយ។

៣. **ធ្វើឲ្យទឹកជ្រាបចូលដី** តាមរយៈការកែលម្អគុណភាពដីដើម្បីឲ្យទឹកច្រោះទៅក្នុងដី។

ជួនកាលយើងពិបាកនឹងសម្គាល់សញ្ញានៃសំណឹកដីណាស់។ សញ្ញានេះរួមមាន ដំណាំដែលផលិតមិនបានច្រើនដូចកាលពីមុន, ទន្លេដែលមានភក់ច្រើនជាងកាលពីមុន(ជាពិសេសក្រោយពេលមានព្យុះ), និងស្រទាប់ដីស្តើងៗ។



**សំណឹកដីទើបតែបង្កើតជាស្នាមភ្លោះតូចមួយប៉ុណ្ណោះ..** **...ប៉ុន្តែមិនយូរប៉ុន្មានស្នាមភ្លោះនឹងក្លាយជាបែបនេះ។**

នៅកន្លែងដែលសំណឹកដីមិនទាន់កើតឡើង យើងអាចបង្ការវាបានដោយការដាំដើមឈើឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន និងដោយការបង្វែរទឹកហូរហៀរលើដីឲ្យទៅក្នុងប្រឡាយ, ត្រពាំង, និងផ្លូវទឹកធម្មជាតិ។ នៅកន្លែងដែលសំណឹកដីមានសភាពធ្ងន់ធ្ងររួចហើយ ក៏យើងនៅតែអាចបញ្ឈប់វា និងកែប្រែដីឡើងវិញដែរ។ សូម្បីតែការរៀបតដ្ឋជាជួរ ឬសង់ជញ្ជាំងថ្មទាបៗនៅលើចំណោតដី ក៏អាចបង្ការដីមិនឲ្យហូរដាច់ទៅក្រោមដែរ ថែមទាំងបង្កើតកន្លែងមានជីជាតិសម្រាប់ដើមឈើនិងរុក្ខជាតិផងដែរ។ មធ្យោបាយកសិកម្មដែលមានស្ថិរភាព, ដូចជាជីបៃតង ចម្ការវិលជុំ កាកសំណល់រុក្ខជាតិ និងការដាំដើមឈើស្របជាមួយដំណាំ, ក៏ជាមធ្យោបាយការពារដី និងថែរក្សាប្រភពទឹកផងដែរ(មើលជំពូក15)។

## បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល រៀនសូត្រពីកសិករ



នៅស្រុកហ្កាល់បាហ្កា ខេត្តខាណាតាកា នៃប្រទេសឥណ្ឌា មានអង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការ ជាមួយកសិករ ដើម្បីបង្ការសំណឹកដីក្នុងស្រែចម្ការរបស់ពួកគេ។ កសិករសង់ជញ្ជាំងថ្មតាមរបៀបបុរាណដើម្បីទប់ដី ប៉ុន្តែមានប្រហោងមួយសម្រាប់ឲ្យទឹកហូរកាត់ គេធ្វើបែបនេះសូម្បីតែក្នុងរដូវខ្យល់មូសុង។

បុគ្គលិកអង្គការសង្កេតឃើញថា ជញ្ជាំងថ្មរបស់កសិករធ្វើឲ្យបាត់បង់ស្រទាប់ដីខ្លះទៅចម្ការខាងក្រោម។ ហើយនៅពេលរៀបជញ្ជាំងថ្មខ្ពស់នៅតាមគែមចម្ការខាងក្រោម ក៏មានធ្លាក់ដុំថ្មខ្លះ ហើយកសិករត្រូវរើសវារៀបឡើងវិញ។ បុគ្គលិកអង្គការស្នើសុំឲ្យសង់ជញ្ជាំងថ្មណែនដែលនឹងមិនឲ្យបាត់បង់ដីសោះតែម្តង និងមិនចាំបាច់ជួសជុលជាប្រចាំដូច្នេះដែរ។

កសិករនិយាយថាពួកគេមិនជំទាស់នឹងការសង់ជញ្ជាំងថ្មថ្មីទេ។ ប៉ុន្តែបុគ្គលិកអង្គការមិនយល់ពីសម្តីនេះ។ ជញ្ជាំងថ្មរបស់កសិករត្រូវការកម្លាំងច្រើនក្នុងការសាងសង់ ហើយវាធ្វើឲ្យបាត់បង់ស្រទាប់ដីខ្លះ ដែលមិនអាចការពារសំណឹកដីបានទាំងស្រុងទេ។ ពួកគេស្នើឲ្យធ្វើពិសោធន៍។ នៅស្រែចម្ការខ្លះពួកគេសាងសង់ជញ្ជាំងថ្មណែនថ្មី។ នៅស្រែចម្ការខ្លះទៀតពួកគេសាងសង់ជញ្ជាំងតាមបែបបុរាណ។

នៅពេលចប់រដូវកាល កសិករនិងបុគ្គលិកអង្គការបានជួបជុំគ្នាដើម្បីប្រៀបធៀបលទ្ធផល។ កសិករជាច្រើនដែលមានស្រែចម្ការនៅខាងក្រោមជញ្ជាំងថ្មណែនថ្មី មិនសប្បាយចិត្តទេ។ គោក្របីឆ្លងកាត់ជញ្ជាំងទាបៗនេះទៅក្នុងស្រែចម្ការរបស់ពួកគេ ហើយក្រោយរដូវខ្យល់មូសុង កសិករទាំងនេះមានស្រទាប់ដីថ្មីៗតិចតួច និងទឹកតិចតួចសម្រាប់ស្រែរបស់ពួកគេ គឺមិនដូចកាលពីមុនទេ។

បញ្ហានេះបាននាំឲ្យមានជម្លោះរវាងម្ចាស់ដីខាងក្រោម និងម្ចាស់ដីខាងលើ។ បទពិសោធន៍នេះបង្ហាញថា ជញ្ជាំងបែបបុរាណរបស់កសិករមានប្រសិទ្ធភាពជាងជញ្ជាំង"កែលម្អ"របស់បុគ្គលិកអង្គការ។ កសិករប្រាប់បុគ្គលិកអង្គការថា ជញ្ជាំងថ្មណែននេះបង្កបញ្ហាជាច្រើន។ តាមរយៈបទពិសោធន៍នេះ បុគ្គលិកអង្គការបានស្វែងយល់ថា ជញ្ជាំងបែបបុរាណរបស់កសិករមិនត្រឹមតែបង្ការសំណឹកដីប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្ការមិនឲ្យសត្វគោក្របីឆ្លងចូលស្រែចម្ការផងដែរ។ ការអនុញ្ញាតឲ្យដីនិងទឹកខ្លះហូរឆ្លងកាត់ជញ្ជាំង រក្សាទំនាក់ទំនងល្អរវាងកសិករនិងអ្នកជិតខាងរបស់ខ្លួន ដែលចំណុចនេះសំខាន់ជាងការពារតិចតួច( លើកថ្មតម្រៀបឡើងវិញ )ទៅទៀត!

# ការកែប្រែដីដែលខូចខាតឡើងវិញ

ជួនកាលដីត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរដែលមើលទៅដូចជាមិនអាចកែប្រែឲ្យមានស្ថានភាពល្អឡើងវិញទេ។ នៅកន្លែងដែលដីល្អបានប្រែក្លាយជាខ្សាច់ ឬសារធាតុគីមីនៅក្នុងដីធ្វើឲ្យមិនអាចដាំដើមឈើបាន, ដីទាំងនេះអាចត្រូវការពេលរាប់រយឆ្នាំដើម្បីមានស្ថានភាពល្អវិញ។ ប៉ុន្តែនៅកន្លែងជាច្រើន, ដោយការធ្វើការងារយ៉ាងប្រុងប្រយ័ត្ន និងការយល់អំពីរបៀបដែលផែនដីកែប្រែគុណភាពដីដោយខ្លួនឯង, យើងអាចជួយដីឲ្យកែប្រែគុណភាពរបស់វាបាន។

គ្មានអ្នកណាម្នាក់អាចបង្ខំដីឲ្យមានផលិតភាពឡើងវិញទេ។ សូម្បីតែជីគីមីក៏មានប្រសិទ្ធភាពតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ បន្ទាប់មកដីនឹងលែងមានផលិតភាពហើយ។ ប៉ុន្តែប្រសិនបើយើងចាប់អារម្មណ៍ទៅលើវដ្តធម្មជាតិវិញ នោះយើងអាចជួយបង្កើតលក្ខខណ្ឌនានាដែលដីត្រូវការដើម្បីកែប្រែខ្លួនវាឡើងវិញឲ្យមានសុខភាពល្អនិងមានជីជាតិ។

## ការលូតលាស់ឡើងវិញតាមធម្មជាតិ

ជួនកាលវិធីល្អបំផុតក្នុងការកែប្រែដី គឺត្រូវទុកវាចោល ឬជួយវាឲ្យស្តាបនាឡើងវិញតាមវិធីតូចតាច។ ការធ្វើរបងព័ទ្ធជុំវិញដី ឬបទស្លាកសញ្ញាហាមមិនឲ្យមនុស្សចូល ឬកាត់បន្ថយចំនួនសត្វដែលស៊ីស្មៅលើដីនោះ អាចចូលរួមជួយដីឲ្យស្តាបនាឡើងវិញ។ នៅពេលដីត្រូវបានការពារមិនឲ្យប្រើប្រាស់ ហើយមានលក្ខខណ្ឌត្រឹមត្រូវសម្រាប់ឲ្យជីវិតត្រឡប់មកវិញ នោះរុក្ខជាតិនឹងចាប់ផ្តើមដុះឡើងវិញតាមលំដាប់លំដោយធម្មជាតិដែលហៅថា "ការលូតលាស់ឡើងវិញតាមធម្មជាតិ"។ ដំណើរការនេះអាចត្រូវការពេលជាច្រើនឆ្នាំ ឬអាចជាច្រើនជំនាន់ទៀតផង។

ការលូតលាស់ឡើងវិញតាមធម្មជាតិ នឹងមិនអាចកែប្រែដីឡើងវិញទេនៅពេលដែល :

- គ្មានប្រភពគ្រាប់ពូជឬរុក្ខជាតិក្នុងតំបន់នៅក្បែរដីនោះទេ។
- រុក្ខជាតិដែលលូតលាស់ឆាប់រហ័ស បានដុះស៊ុបទ្រុបលើរុក្ខជាតិដែលត្រូវការ។
- ដីបានបំផ្លាញនិងបំពុលខ្លាំងពេកដែលគ្មានរុក្ខជាតិអ្វីអាចដុះឡើងវិញបាន។ (សម្រាប់សាច់រឿងអំពីការកែប្រែដីបន្ទាប់ពីកំពប់ប្រេង សូមមើលទំព័រ520)។



## រុក្ខជាតិនិងដើមឈើក្នុងតំបន់ និងក្រៅតំបន់

រុក្ខជាតិក្នុងតំបន់ អាចលូតលាស់យ៉ាងងាយស្រួលក្នុងលក្ខខណ្ឌក្នុងតំបន់។ វាក៏រក្សាជីវចម្រុះផងដែរ តាមរយៈការទាក់ទាញ និងផ្តល់ជម្រកដល់សត្វល្អិត សត្វស្លាប និងសត្វព្រៃដែលមានដើមកំណើតនៅក្នុងតំបន់នោះ។

ជួនកាលរុក្ខជាតិនិងដើមឈើក្រៅតំបន់ ក្លាយជាមានប្រជាប្រិយភាពព្រោះវាលូតលាស់ឆាប់រហ័ស ផ្តល់ឈើអារល្អ ឬជួយកែលម្អដី។ ដើមឈើខ្លះ ដូចជាដើមប្រេងខ្យល់ ដើមស្រល់ និងដើមម៉ែស៉ក ត្រូវបានដាំនៅទូទាំងពិភពលោក។

ប៉ុន្តែការដាំដើមឈើនិងរុក្ខជាតិក្រៅតំបន់របស់អ្នក អាចនាំឲ្យមានបញ្ហា។ ពួកវាអាចប្រើប្រាស់ទឹកក្នុងដីយ៉ាងច្រើន, ប្រជែងជាមួយដំណាំនិងរុក្ខជាតិក្នុងតំបន់របស់អ្នក ដោយដណ្តើមយកទឹកនិងជីមានជីជាតិ, លូតលាស់ហួសកន្លែងដែលអ្នកចង់ឲ្យវាលូតលាស់ទៅទៀត, ឬធ្វើឲ្យសត្វព្រៃនិងសត្វល្អិតក្នុងតំបន់ រត់ទៅរស់នៅកន្លែងដទៃទៀត។ នៅពេលរុក្ខជាតិក្រៅតំបន់បានកាន់កាប់លើព្រៃហើយ នោះការដុះឡើងវិញតាមធម្មជាតិ នឹងពិបាកកែប្រែឡើងវិញណាស់។

## ការលូតលាស់ឡើងវិញតាមធម្មជាតិ



១. ដីដែលត្រូវបានកាប់ដើមឈើបំផ្លាញ
ដែលមានដីមិនល្អ និងគ្មានជីវិតរុក្ខជាតិ។



២. រុក្ខជាតិតូចៗ ហៅថារុក្ខជាតិត្រួសត្រាយ លូតលាស់
មកមុនគេនៅក្នុងក្រហែងដីមានស្រទាប់ដីបន្តិចបន្តួច។
រុក្ខជាតិត្រួសត្រាយស្រូបយកទឹក និងទាក់ទាញសត្វល្អិត
និងសត្វស្លាប។



៣. ទឹកជ្រាបចូលក្រោមរុក្ខជាតិ
ត្រួសត្រាយ ធ្វើឲ្យមានគ្រាប់
និងសារធាតុចិញ្ចឹម។ សត្វ
ស្លាបជួយធ្វើឲ្យមានគ្រាប់។



៤. រុក្ខជាតិធំៗនិងដើមឈើតូចៗ
ចាប់ផ្តើមលូតលាស់។ ឫសរុក្ខជាតិ
ចាក់ចូលក្នុងដីរឹង។ ស្រទាប់ដី
ចាប់ផ្តើមកកើត និងប្រមូលទឹក
កាន់តែច្រើន។



៥. ដើមឈើនិងគុម្ពឈើធំៗដុះមកវិញ
ហើយដីត្រូវបានកែប្រែឡើងវិញ។

## វិធីធ្វើដុំគ្រាប់ពូជ

មធ្យោបាយសាមញ្ញមួយក្នុងការស្រោចស្រង់ជីវិតរុក្ខជាតិឡើងវិញ គឺការប្រើដុំគ្រាប់ពូជ។ គួរប្រមូលគ្រាប់ពូជក្នុងព្រៃរាល់ថ្ងៃ។ កុមារពូកែរកគ្រាប់ពូជជាងគេ ហើយវាជាសកម្មភាពរៀនសូត្រមួយដែលគួរឲ្យសប្បាយ។

ប្រមូលគ្រាប់ពូជផ្សេងៗគ្នានៃរុក្ខជាតិក្នុងតំបន់។ ធ្វើដុំគ្រាប់ពូជដោយលាយគ្រាប់ពូជជាមួយដីខ្លះ។

លាយ :



**គ្រាប់ពូជចម្រុះ ១ភាគ** | **ដីកំប៉ុសដែលរលួយរួច ឬដីមានជីជាតិ ២ភាគ** | **ដីឥដ្ឋមិនមានគ្រួស ៣ភាគ** | **ទឹកបន្តិចបន្តួច**

លាយគ្រាប់ពូជជាមួយដីកំប៉ុស ឬដីមានជីជាតិ រួចដាក់ដីឥដ្ឋ។ ថែមទឹកឲ្យល្មមតែសើម។ ប្រសិនបើអ្នកថែមទឹកច្រើនពេក គ្រាប់ពូជនឹងចេញពន្លកឆាប់ពេក។ លុញល្បាយនេះជាដុំតូចៗ។ ហាលថ្ងៃវាឲ្យស្ងួតពីរបីថ្ងៃ។



ពេលរដូវភ្លៀងមកដល់ ចូរទៅកន្លែងដែលអ្នកចង់ស្រោចស្រង់ជីវិតរុក្ខជាតិឡើងវិញ រួចបោះរាយដុំគ្រាប់ពូជទាំងនេះ។ គួរសាងសង់ប្រឡាយ និងរបាំងដទៃទៀតជាមុន(មើលទំព័រ293) ដើម្បីឲ្យវានាំទឹកទៅស្រោចស្រប់គ្រាប់ពូជ។

គ្រាប់ពូជទាំងនេះនឹងចេញពន្លកនៅពេលភ្លៀង។ ដីកំប៉ុសផ្តល់សារធាតុចិញ្ចឹម ហើយដីឥដ្ឋបង្ការគ្រាប់ពូជមិនឲ្យស្ងួត មិនឲ្យកណ្តុរឬសត្វស្លាបស៊ី ឬមិនឲ្យហូរតាមទឹក។ មួយឆ្នាំក្រោយមក រុក្ខជាតិថ្មីៗនេះនឹងបង្កើតគ្រាប់ពូជដោយខ្លួនវា ហើយក្នុងពេលឆាប់ៗរុក្ខជាតិថ្មីៗជាច្រើននឹងលូតលាស់។ ស្រទាប់ដីនឹងករកើតនៅជុំវិញរុក្ខជាតិដើម្បីបង្ការសំណឹកដី។ មិនយូរទេ រុក្ខជាតិប្រភេទដទៃៗទៀតនឹងដុះឡើងមកដែរ។ ប្រសិនបើដំណើរការនេះមិនមានការរំខានទេ តំបន់ទាំងមូលនឹងត្រូវបានកែប្រែឡើងវិញក្នុងប៉ុន្មានឆ្នាំក្រោយមក។



## ការជួយដើមឈើឲ្យលូតលាស់ដោយខ្លួនឯង

នៅប្រទេសសូម៉ាលី ដែលស្ថិតនៅទ្វីបអាហ្វ្រិកខាងកើត មានដើមឈើតិចតួចប៉ុណ្ណោះ ដោយសារតែបរិយាកាសស្ងួត និងវាលខ្សាច់។ ប៉ុន្តែចំនួនដើមឈើមានកាន់តែស្តួចស្តើងថែមទៀត ដោយសារឈើទាំងនេះត្រូវបានកាប់ធ្វើជាធ្យូងឧស។ ធ្យូងឧសមួយចំនួនត្រូវបានប្រើប្រាស់ដោយប្រជាជនសូម៉ាលី ប៉ុន្តែធ្យូងឧសភាគច្រើនត្រូវបានលក់ទៅប្រទេសដទៃទៀត។ នៅពេលស្ត្រីម្នាក់ឈ្មោះហ្វាទីម៉ាជីប្រ៊ែលៃ បានឃើញបញ្ហានេះ គាត់ក៏ចាប់ផ្តើមយុទ្ធនាការមួយដើម្បីបង្ការការលក់ធ្យូងឧសទៅប្រទេសដទៃ។ គាត់និយាយថា "នៅពេលយើងមានធនធានស្ទើរតែមិនគ្រប់ខ្លួនឯងផង យើងមិនអាចឲ្យអ្នកដទៃមកយកផលប្រយោជន៍ពីធនធានរបស់យើងបានទេ"។

យុទ្ធនាការរបស់ហ្វាទីម៉ាបានទទួលជោគជ័យ។ ប៉ុន្តែទម្រាំតែដល់ពេលនេះ មានដើមឈើតិចតួចបំផុតដែលនៅសេសសល់។ ដូច្នេះគាត់ក៏ចាប់ផ្តើមយុទ្ធនាការមួយទៀតដើម្បីបំផុសឲ្យមានការដាំដើមឈើថ្មីៗនៅក្នុងប្រទេសសូម៉ាលី។ គាត់ជឿជាក់ថាវិធីប្រសើរបំផុតក្នុងការកាត់បន្ថយភាពក្រីក្រដ៏ធ្ងន់ធ្ងររបស់ប្រជាជនគាត់ គឺការមានដើមឈើឡើងវិញនៅក្នុងប្រទេសសូម៉ាលី។

ដីក្នុងប្រទេសសូម៉ាលីមានលក្ខណៈក្តៅខ្លាំងនិងស្ងួត ធ្វើឲ្យពិបាកដាំដើមឈើ។ ម្យ៉ាងទៀតដោយសារប្រជាជនភាគច្រើនក្នុងប្រទេសសូម៉ាលី តែងតែផ្លាស់ប្តូរទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀតតាមរដូវកាល ដូច្នេះវាជាការពិបាកណាស់ក្នុងការរំពឹងថាពួកគេនឹងដាំដើមឈើហើយមើលថែវានោះ។ ដូច្នេះហ្វាទីម៉ាបានចាប់ផ្តើមបង្រៀនប្រជាជនឲ្យរៀបរបងថ្មក្នុងពេលដែលពួកគេធ្វើដំណើរក្នុងប្រទេស។ ទោះបីដីមានលក្ខណៈរាបស្មើក៏ដោយ ហ្វាទីម៉ាជឿជាក់ថាទឹកនឹងហូរទៅរកកន្លែងទំនាប ហើយនឹងនាំជីវិតមកជាមួយផងដែរ។ ក្នុងរដូវភ្លៀងដ៏ខ្លី របងថ្មទាំងនេះបានជួយបង្កើនជីជាតិរបស់ដី ហើយរុក្ខជាតិនិងដើមឈើក៏ចាប់ផ្តើមលូតលាស់ដោយខ្លួនឯង។ សព្វថ្ងៃមានដើមឈើលូតលាស់នៅក្នុងប្រទេសសូម៉ាលី ច្រើនជាងកាលពីប៉ុន្មានឆ្នាំមុន។



# ការដាំដើមឈើ

ក្នុងលក្ខខណ្ឌត្រឹមត្រូវ ការដាំដើមឈើជួយឲ្យកែប្រែដីដែលខូចខាតឡើងវិញ និងផ្តល់ជាឧសដុត, ឈើ, អាហារសម្រាប់មនុស្សនិងសត្វ, និងឱសថ។ ការដាំដើមឈើអាចធ្វើឲ្យដីដែលគ្មានជីជាតិនិងសោះកក្រោះឲ្យប្រែជាសម្បូរជីជាតិឡើងវិញ។ ប៉ុន្តែដើមឈើដែលបានដាំក្នុងលក្ខខណ្ឌអាក្រក់ ត្រូវការការថែទាំដើម្បីអាចលូតលាស់បានល្អ។ ការដាំដើមឈើមានផលប្រយោជន៍ជាច្រើន ប៉ុន្តែវាមិនមែនតែងតែត្រឹមត្រូវចំពោះតំបន់ទាំងអស់ឬសហគមន៍ទាំងអស់នោះទេ(មើលទំព័រ191អំពីសកម្មភាពដែលអាចជួយអ្នកក្នុងការសម្រេចចិត្តថាតើគួរដាំដើមឈើឬមិនគួរ)។

មានវិធីច្រើនយ៉ាងក្នុងការដាំដើមឈើ :

- ដាំគ្រាប់ពូជឬកំណាត់មែកឈើដោយផ្ទាល់ទៅក្នុងដី(មើលទំព័រ207)។
- ប្រមូលនិងផ្សាំកូនឈើ(មើលទំព័រ208)។
- បណ្តុះកូនឈើ រួចផ្សាំវាក្នុងដី(មើលទំព័រ209)។
- យកកំណាត់មែកឈើដែលអ្នកចង់បាន មកបំបៅជាមួយឫសនៃដើមឈើមួយទៀត។ (ជាទូទៅវិធីបំបៅមែកឈើត្រូវបានប្រើក្នុងការដាំដើមឈើហូបផ្លែ ហើយសៀវភៅនេះមិនមានពន្យល់ពីវិធីនេះទេ)។

មធ្យោបាយដែលអ្នកជ្រើសរើស អាស្រ័យលើប្រភេទដើមឈើដែលអ្នកចង់ដាំ និងនៅលើថាតើគ្រាប់ពូជនិងមែកឈើអ្វីខ្លះដែលអាចរកបាន។



## ការជ្រើសរើសគ្រាប់ពូជឬមែកឈើ

មនុស្សជាច្រើនមានសុភាសិតមួយដែលនិយាយថា "ស្រឡាញ់ឪពុកម្តាយ ស្រឡាញ់កូន"។ កុមារដែលមានឪពុកម្តាយខ្ពស់ៗ ទំនងជានឹងលូតលាស់បានខ្ពស់ដែរ។ យ៉ាងណាមិញ កូនឈើដែលមេរបស់វាមានដើមត្រង់ដែលល្អសម្រាប់ឈើអារ ឬផ្តល់ឱសថមានប្រយោជន៍, កូនឈើនេះទំនងជានឹងមានគុណភាពដូចដើមមេដែរ។ ប្រសើរបំផុតគួរប្រមូលគ្រាប់ពូជឬមែកឈើពីដើមមេដែលលូតលាស់យ៉ាងល្អនិងមានគុណភាពដែលអ្នកត្រូវការ។ ប្រសិនបើអ្នកមិនអាចរកគ្រាប់ពូជនៅក្នុងតំបន់អ្នកទេ អ្នកប្រហែលជាអាចរកនៅកន្លែងបណ្តុះកូនឈើ ឬនៅសួនច្បារក្នុងក្រុងជិតខាង។

# ការរៀបចំគ្រាប់ពូជសម្រាប់ដាំ

គ្រាប់ពូជខ្លះ, ជាទូទៅពពួកដែលមានសម្បកទន់ និងគ្រើមៗឬសើម, ចាំបាច់ត្រូវដាំវាឲ្យបានឆាប់បន្ទាប់ពីប្រមូលយកមក។ គ្រាប់ដទៃទៀតអាចត្រូវការរក្សាទុករយៈពេលច្រើនខែមុននឹងដាំវា។ (សម្រាប់ព័ត៌មានបន្ថែមអំពីការរក្សាទុកគ្រាប់ពូជ សូមមើលទំព័រ303)។



គ្រាប់ពូជភាគច្រើនត្រូវការទឹកដើម្បីចេញពន្លក។ នៅពេលគ្រាប់ពូជមានសម្បកក្រាស់ឬរឹង នោះយើងប្រហែលជាត្រូវបន្ទន់សម្បក ឬកាត់វាចោល ទើបទឹកអាចជ្រាបចូលបាន។ គ្រាប់ពូជខ្លះអាចត្រូវការជំនួយបន្ថែមទៀតមុននឹងអាចដាំបាន។

- ប្រសិនបើសម្បកគ្រាប់ពូជមិនសូវរឹង(អ្នកអាចពត់ឬកាច់វាបានដោយប្រើក្រចកដៃ) និងមិនសូវក្រាស់ទេ(មិនក្រាស់ជាងគម្របសៀវភៅនេះ) អ្នកអាចដាំវាដោយផ្ទាល់ទៅក្នុងដីសើម។



- ប្រសិនបើសម្បកគ្រាប់ពូជរឹងប៉ុន្តែស្តើង ត្រូវរុំគ្រាប់ពូជទាំងនេះនៅក្នុងក្រណាត់។ ជ្រលក់ទឹកក្តៅ(ប៉ុន្តែមិនទាន់ពុះ, ៨0°C)រយៈពេល១នាទី។ ដកវាចេញពីទឹកក្តៅឲ្យឆាប់ រួចត្រាំក្នុងទឹកត្រជាក់មួយយប់។ ដាំវានៅថ្ងៃបន្ទាប់។
- វិធីមួយទៀតក្នុងការបន្ទន់សម្បកគ្រាប់ពូជដែលរឹងប៉ុន្តែស្តើង គឺត្រូវត្រាំវានៅក្នុងទឹកត្រជាក់ពេញ១ថ្ងៃ បន្ទាប់មកខ្ចប់វាក្នុងក្រណាត់សើមរយៈពេល២៤ម៉ោងទៀត។ ធ្វើដដែលៗឡើងវិញរយៈពេល៦ថ្ងៃ។ នៅថ្ងៃទី៧ អ្នកអាចដាំគ្រាប់ពូជបាន។



- ប្រសិនបើសម្បកក្រាស់និងរឹង ត្រូវត្រដុសវាជាមួយនឹងថ្មគ្រើមឬក្រដាស់ខាត់ រហូតទាល់តែមើលឃើញផ្នែកទន់នៅខាងក្នុងគ្រាប់។ ត្រូវប្រយ័ត្នកុំត្រដុសឲ្យដាច់ច្រើនពេក ឬធ្វើឲ្យខូចគ្រាប់ពូជ។



- ប្រសិនបើសម្បកទន់ប៉ុន្តែក្រាស់ ចូរចៀរបន្ទះស្តើងនូវផ្នែកទន់ខាងក្នុងគ្រាប់ ដោយប្រយ័ត្នចៀរសាច់គ្រាប់ឲ្យតិចបំផុត។
- ចំពោះគ្រាប់ពូជខ្លះដែលមានសម្បកក្រាស់ ល្អបំផុតគឺត្រូវត្រាំទឹកលាយជាមួយលាមកគោរយៈពេល១យប់ បន្ទាប់មកហាលថ្ងៃឲ្យស្ងួតរយៈពេល១ថ្ងៃ។ ធ្វើដដែលៗឡើងវិញរយៈពេល៣ទៅ៤ថ្ងៃ។ គ្រាប់ពូជដែលល្អនឹងចេញពន្លក ហើយរួចរាល់សម្រាប់ដាំ។ គ្រាប់ពូជដែលមិនចេញពន្លក អាចបោះវាចោលបាន។

គ្រាប់ពូជខ្លះត្រូវការជំនួយស្មុគស្មាញ ដូចជាការអាំងភ្លើង ដាក់ឲ្យត្រជាក់ ឬឲ្យសត្វស៊ីរួចចាំយកលាមកវាវិញ។ ចូរធ្វើការពិសោធន៍ដើម្បីរកមើលថាតើវិធីណាមានប្រសិទ្ធភាពបំផុត។ បន្ទាប់ពីព្យាយាមច្រើនដង អ្នកនឹងក្លាយជាអ្នកជំនាញផ្នែកបណ្តុះគ្រាប់ពូជ។

## ការរៀបចំកំណាត់មែកឈើ




ដើមឈើខ្លះលូតលាស់បានល្អបំផុតដោយការដាំកំណាត់មែកឈើទៅក្នុងដី រួចស្រោចទឹកវារហូតទាល់តែវាចេញឫសនិងស្លឹក។ ដើមឈើដែលលូតលាស់ចេញពីមែកឈើ ជាទូទៅចេញផ្លែឬគ្រាប់ បានឆាប់ជាងដើមឈើដែលលូតលាស់ចេញពីគ្រាប់ពូជ។

មែកឈើខ្លះអាចដាំដោយផ្ទាល់ទៅក្នុងដីដែលអ្នកចង់ឲ្យវាដុះ។ មែកឈើខ្លះទៀតគួរតែបណ្តុះនៅមណ្ឌលបណ្តុះកូនឈើ រហូតទាល់តែវាចេញស្លឹកនិងឫសជាច្រើន និងអាចរស់រានដោយខ្លួនវាបាន។

កាប់មែកឈើត្រង់កណ្តាល, យកមែកដែលពត់បានតិចៗ ប៉ុន្តែក៏មិនមែនរឹងឆ្អឹងដែរ។ កាត់យកមួយកំណាត់ដែលមានថ្នាំង(កំពកនៅលើមែកដែលស្លឹកដុះឬធ្លាប់ដុះតាមនេះ)ពី៦ទៅ១០។ យកស្លឹកឈើចេញថ្នមៗដោយប្រយ័ត្នមិនឲ្យខូចថ្នាំង។ កាប់មែកដែលដុះផ្ទៀងបន្តិច, ជាជាងមែកដែលដុះត្រង់ស្របផ្ទៃដី, ដើម្បីជួយឲ្យវាចេញឫសបានល្អ។

ទោះបីមែកឈើត្រូវបានបណ្តុះនៅមណ្ឌលបណ្តុះកូនឈើ ឬដាំទៅក្នុងដីដោយផ្ទាល់ក៏ដោយ ត្រូវប្រាកដថាវាមានទឹកច្រើន និងបានការពារពីសត្វល្អិតរហូតទាល់តែវាចេញឫសគ្រប់គ្រាន់អាចស្វែងរកទឹកដោយខ្លួនឯង។



ការយកកូនឈើពីក្នុងព្រៃមកផ្សាំ

## ការផ្សាំកូនឈើព្រៃ

វិធីមួយទៀតក្នុងការបង្កើតព្រៃឈើ គឺការជីកយកកូនឈើពីក្នុងព្រៃ យកមកដាំកន្លែងផ្សេងដែលអ្នកចង់បាន។ រកមើលដើមមេដែលដុះយ៉ាងល្អ រួចជ្រើសរើសកូនឈើដែលដុះនៅក្បែរឬនៅក្រោមមេវា។

ជីកកូនឈើតូចៗដោយប្រយ័ត្នកុំឲ្យដាច់ឫសកែវរបស់វា។ ប្រសិនបើដាច់ឫសនេះ ដើមឈើនឹងមិនលូតលាស់ល្អទេ។ ជីកដីជារង្វង់ជុំវិញកូនឈើ និងជីកចុះក្រោមឲ្យជ្រៅតាមដែលអ្នកគិតថាឫសកែវរបស់វាអ្នកចាក់ចុះដល់។ ប្រើដៃឬឧបករណ៍អ្វីមួយដើម្បីលើកយកវាឲ្យនឹង មិនឲ្យរង្គើជ្រុះដីជុំវិញឫសវា។

រក្សាសំណើមនៃដីជុំវិញឫសឈើ រហូតទាល់តែដល់ពេលដាំទៅក្នុងដី។ បន្តស្រោចទឹកវារហូតទាល់តែឫសរបស់វាចាក់ក្នុងកន្លែងថ្មី ហើយអាចរកទឹកដោយខ្លួនឯង។

# ការបណ្ដុះឈើនៅមណ្ឌលបណ្ដុះកូនឈើ

មណ្ឌលបណ្ដុះកូនឈើ ផ្ដល់ការចាប់ផ្ដើមដ៏ល្អដល់កូនឈើមុននឹងយកទៅផ្សាំនៅកន្លែងផ្សេង។ ប៉ុន្តែការបណ្ដុះនិងការថែទាំកូនឈើអាចជាការងារដែលស៊ីពេលច្រើន។ លក្ខខណ្ឌដែលអ្នកគួរបណ្ដុះឈើនៅមណ្ឌលបណ្ដុះ គឺនៅពេលណាដែល :

- គ្រាប់ឬមែកឈើដែលអ្នកចង់ដាំ កំពុងខ្វះខាត។
- សត្វល្អិតនឹងបំផ្លាញកូនឈើប្រសិនបើមិនការពារវា។
- បុគ្គលិកមានពេលគ្រប់គ្រាន់ក្នុងការថែទាំនៅមណ្ឌលបណ្ដុះកូនឈើ។

ការដាំដើមឈើដោយផ្ទាល់ ងាយស្រួលជាងការបណ្ដុះវាជាមុននៅមណ្ឌលបណ្ដុះកូនឈើ រួចផ្សាំវាជាក្រោយ។ ប៉ុន្តែការដាំដោយផ្ទាល់មានងាប់កូនឈើច្រើនជាងការបណ្ដុះនៅមណ្ឌលបណ្ដុះកូនឈើ។

## គួរចាប់ផ្ដើមដាំឈើនៅពេលណា

ពេលវេលាដែលអ្នកដាំដើមឈើ គឺអាស្រ័យលើរយៈពេលដែលវាត្រូវស្ថិតនៅក្នុងមណ្ឌលបណ្ដុះកូនឈើ។ ប្រសិនបើតំបន់របស់អ្នកមានរដូវប្រាំងនិងរដូវវស្សា ចូរដាំដើមឈើនៅពេលរដូវវស្សាចាប់ផ្ដើមភ្លាម ដូច្នេះអ្នកនឹងមិនចាំបាច់ស្រោចទឹកវាច្រើនពេក។ ដើមឈើភាគច្រើនត្រូវស្ថិតក្នុងមណ្ឌលបណ្ដុះកូនឈើពី៣ទៅ៤ខែ មុននឹងវាលូតលាស់ធំល្មមអាចដាំនៅកន្លែងផ្សេង។

## គួរបង្កើតមណ្ឌលបណ្ដុះកូនឈើនៅទីណា

មណ្ឌលបណ្ដុះកូនឈើគួរធ្វើនៅកន្លែងណាដែលមនុស្សអាចទៅរកបានយ៉ាងងាយ និងដំណើរការយ៉ាងយូរ ដែលផ្ដល់ពេលគ្រប់គ្រាន់ក្នុងការបណ្ដុះឈើមុននឹងយកទៅផ្សាំនៅកន្លែងផ្សេង។ មនុស្សដែលនឹងធ្វើការនៅក្នុងមណ្ឌលបណ្ដុះកូនឈើ ក៏គួរតែអាចធ្វើដំណើរទៅទីនោះបានយ៉ាងងាយដែរ។ មណ្ឌលបណ្ដុះកូនឈើទាំងអស់ត្រូវមានលក្ខណៈទាំងនេះ :



## ការបណ្តុះកូនឈើនៅក្នុងផើង

ការបណ្តុះកូនឈើនៅក្នុងផើង ធ្វើឲ្យយើងអាចជញ្ជូននិងដាំវាបានយ៉ាងងាយ។ ផើងទាំងនេះគួរមានមុខកាត់ខាងលើនិងជម្រៅល្មមនឹងឲ្យកូនឈើដុះឫស ប៉ុន្តែមិនត្រូវធំពេកដែលធ្វើឲ្យធ្ងន់ៗជក់ទឹកច្រើនលើសតម្រូវការរបស់កូនឈើទេ។

កាលណាកូនឈើត្រូវស្ថិតនៅក្នុងមណ្ឌលបណ្តុះកូនឈើកាន់តែយូរ នោះអ្នកត្រូវធ្វើផើងវាកាន់តែធំដែរ។ ទំហំដែលល្អសម្រាប់កូនឈើភាគច្រើន គឺមុខកាត់ខាងលើប្រហែល១៥ស.ម និងជម្រៅប្រហែល ២៣ស.ម។ ផើងទាំងនេះគួរមានកម្លាំងគ្រប់គ្រាន់អាចទប់ទល់នឹងទម្ងន់បាននៅពេលដាក់ដីពេញ និងគួរមានរន្ធតូចៗពីក្រោមដើម្បីឲ្យទឹកដែលលើសលុបហូរចេញ។



**ផើងដែលនឹងរលួយ(ក្រដាសកាសែត ស្លឹកឈើ ប្រអប់ឡាំង) អាចត្រូវបានដាំដោយផ្ទាល់ទៅក្នុងដីជាមួយនឹងកូនឈើ។ ផើងដែលធ្វើពីប្លាស្ទិក កែវ ឬឈើ ត្រូវយកវាចេញមុនពេលដាំ ប៉ុន្តែអាចយកប្រើដើម្បីបណ្តុះកូនឈើឡើងវិញជាច្រើនដងទៀត។**

កូនឈើតូចៗចាំបាច់ត្រូវការពារពីកម្តៅថ្ងៃខ្លាំងពេក។ កូនឈើជាច្រើនលូតលាស់បានល្អនៅក្រោមម្លប់នៅពេលថ្ងៃត្រង់។

## ដីសម្រាប់ដាំឈើ

ដីដែលប្រើសម្រាប់ដាំឈើ គួរតែមានលក្ខណៈផុសៗ ដើម្បីកុំឲ្យឫសកូនឈើរលួយ។ ដីនេះក៏ត្រូវសម្បូរសារធាតុចិញ្ចឹមដែរ(មើលទំព័រ282) ដើម្បីឲ្យដើមឈើលូតលាស់ល្អ។ ដីក្នុងព្រៃ ឬដីពីរបត់នៃទន្លេឬខ្សែទឹក គឺជាដីដ៏ល្អសម្រាប់កូនឈើ។






**ការរែងដីសម្រាប់ដាំរុក្ខជាតិ**

### វិធីបណ្ដុះគ្រាប់ពូជឬមែកឈើនៅក្នុងផើង

1. ស្រោចទឹកលើដីដែលដាំកូនឈើមួយថ្ងៃមុននឹងដាំ ដើម្បីឲ្យដីមានសំណើមប៉ុន្តែមិនសើមជោគទេ។ ជួយបន្ទន់គ្រាប់ពូជជាមុន ប៉ុន្តែកុំឲ្យយូរពេកព្រោះវាអាចចេញពន្លកឬរលួយ (មើលទំព័រ304)។ ដាក់ដីចូលផើង។

2. ដើម្បីបណ្ដុះគ្រាប់ពូជតូចៗ ចូរកាយផ្ទៃដី រោយគ្រាប់ពូជ៥ឬ១០គ្រាប់ រួចគ្របដីពីលើស្ដើងៗដោយការកាយដីម្ដងទៀតដោយប្រើសម ឬកំណាត់ឈើ។

   ដើម្បីបណ្ដុះគ្រាប់ពូជធំៗ ចូរចោះរន្ធមួយនៅកណ្ដាលដី ប្រហែល២ទៅ៣ដងជ្រៅជាងប្រវែងគ្រាប់ពូជ។ អ្នកអាចបណ្ដុះច្រើនជាងមួយគ្រាប់នៅក្នុងផើងនីមួយៗ។ គ្របដីពីលើគ្រាប់ពូជរួចសង្កត់វាស្រាលៗ។ ការសង្កត់ដីដូចនេះ គឺដើម្បីកុំឲ្យមានខ្យល់ក្នុងដីដែលធ្វើឲ្យមានមេរោគផ្សិត។



3. ស្រោចទឹកក្នុងផើងបន្ទាប់ពីដាក់គ្រាប់ចូល។ ប្រសិនបើគ្រាប់តូចខ្លាំង ត្រូវស្រោចទឹកយ៉ាងប្រុងប្រយ័ត្នដើម្បីកុំឲ្យវាខ្ចាតចេញ។

4. នៅពេលគ្រាប់ពូជទាំងនោះចេញស្លឹក១ឬ២ ចូរជ្រើសរើសយកកូនឈើតែ១ប៉ុណ្ណោះដែលវាមើលទៅដូចជារឹងមាំជាងគេ រួចកាត់កូនឈើផ្សេងៗចោល ដោយទុកតែកូនឈើមួយដើមប៉ុណ្ណោះនៅក្នុងផើងមួយ។ តាមរយៈការកាត់កូនឈើដែលមិនចង់បានចោល ជាជាងដកវាចេញ គឺអ្នកនឹងមិនរំខានដល់ឫសរបស់កូនឈើដែលអ្នកចង់បាន។

## ការស្រោចទឹកកូនឈើ

ការស្រោចទឹកកូនឈើគឺជាសកម្មភាពដ៏សំខាន់បំផុតមួយនៅក្នុងមណ្ឌលបណ្ដុះកូនឈើ។ ស្រោចទឹកកូនឈើរបស់អ្នកតាមរបៀបមួយដែលសាចទឹកថ្នមៗដូចទឹកភ្លៀង ជាជាងការចាក់បង្ហូរដូចទឹកទុយោដែលអាចធ្វើឲ្យខ្ចាតដី និងរំលើងឫសឈើ។

បរិមាណទឹកដែលកូនឈើត្រូវការ គឺអាស្រ័យលើជម្រៅនៃឫសនៅក្នុងដី។ គួរស្រោចទឹកកូនឈើភ្លាមនៅពេលស្លឹកវាចាប់ផ្ដើមទន់ធ្លាក់។ ប៉ុន្តែល្អបំផុតគឺមិនគួរទុកឲ្យដល់ចំណុចនេះទេ ព្រោះវាដូចជាតានតឹងចំពោះកូនឈើ។

គួរស្រោចទឹកនៅពេលណាស្រទាប់ខាងលើនៃដីហាក់ដូចជាស្ងួតទាំងស្រុង រហូតទាល់តែកូនឈើមានស្លឹក២ឬ៣សន្លឹក។

បន្ទាប់មកស្រោចទឹកនៅពេលណាដីរបស់វាស្ងួតអស់ជម្រៅមួយក្រចកម្រាមដៃមេ រហូតទាល់តែកូនឈើមានស្លឹក៥ឬ៦សន្លឹក។

បន្ទាប់មកស្រោចទឹកនៅពេលណាដែលដីស្ងួតអស់ជម្រៅមួយគន្លាក់ម្រាមដៃមេ រហូតទាល់តែឫសរបស់វាចាក់បាតផើង។




## ការកាត់ស្មៅ និងការដាក់ជី

ស្មៅប្រជែងជាមួយកូនឈើ ដោយវាដណ្ដើមពន្លឺ ទឹក និងសារធាតុចិញ្ចឹមពីដី។ ស្មៅតែបន្តិចបន្តួចនៅក្នុងផើងនឹងមិនបង្កគ្រោះថ្នាក់ទេ។ ប៉ុន្តែបើវាមានច្រើនត្រូវកាត់វាចោលនៅត្រឹមកំពូលដី ដើម្បីកុំឲ្យបែកដី។

បើដីរបស់អ្នកមានជីជាតិ កូនឈើគួរអាចទទួលបានសារធាតុចិញ្ចឹមគ្រប់គ្រាន់។ បើត្រូវការជី គួរធ្វើជីធម្មជាតិពីលាមកសត្វ ជីកំប៉ុស ឬទឹកនោម(មើលជំពូក15)។

## ការផ្សាំកូនឈើ

នៅពេលឫសកូនឈើចាប់ផ្តើមចាក់បាតថើង (ជាធម្មតា៣ទៅ៤ខែបន្ទាប់ពីបណ្តុះ) នោះដល់ពេលត្រូវផ្សាំវាហើយ។ ប្រសិនបើអ្នកមិនអាចដាំវាក្នុងពេលនេះទេ ចូរកាត់តម្រឹមឫសរបស់វាមួយអាទិត្យម្តង។ ធ្វើបែបនេះជួយកូនឈើឲ្យមានឫសពេញ១ជុំនៅក្នុងថើង និងជួយវាឲ្យបន្តចាក់ឫសក្នុងដី។




**ការដាំក្នុងទម្រង់ជាត្រីកោណ ធ្វើឲ្យមានដើមឈើច្រើនដុះនៅក្នុងតំបន់តូចមួយ។**

មួយខែមុននឹងផ្សាំកូនឈើ ត្រូវកាត់បន្ថយម្លប់បន្តិចម្តងៗពីលើកូនឈើ រហូតទាល់តែវាមានកម្រិតពន្លឺថ្ងៃដូចគ្នានឹងកន្លែងដែលនឹងផ្សាំវា។ ធ្វើដូចនេះជួយកូនឈើឲ្យសម្របខ្លួនជាមួយស្ថានភាពនៅកន្លែងផ្សាំដែលវាក្តៅជាងនិងស្ងួតជាងមណ្ឌលបណ្តុះ។

មួយថ្ងៃមុននឹងផ្សាំ ត្រូវស្រោចទឹកកូនឈើដើម្បីឲ្យសើមថើង។ ផ្សាំវាដោយប្រុងប្រយ័ត្ន ដោយប្រាកដថានឹងមិនធ្វើឲ្យខូចឫស។ គូសចំណាំលើកន្លែងដែលអ្នកចង់ដាំកូនឈើនីមួយៗ។ គម្លាតពីកូនឈើនីមួយៗអាស្រ័យលើប្រភេទកូនឈើ និងមូលហេតុនៃការដាំ។ តាមក្បួនទូទៅ ចូរដាំដើមឈើឲ្យឃ្លាតល្មមតែមែករបស់វាប៉ះគ្នាប៉ុណ្ណោះនៅពេលលូតលាស់ពេញរូបរាង។

សម្អាតស្មៅឬគុម្ពោធដែលអាចបាំងពន្លឺថ្ងៃដល់កូនឈើ ឬដែលអាចដណ្តើមទឹកពីកូនឈើ ដោយសម្អាតវាក្នុងបរិវេណប្រហែល១ម៉ែត្រជុំវិញកន្លែងកូនឈើ។ ដាំវាក្នុងពេលព្រឹកព្រលឹម ឬនៅពេលរសៀលដែលត្រជាក់ ដើម្បីការពារកូនឈើពីកម្តៅថ្ងៃ។ ចៀសវាងការធ្វើឲ្យឫសខូចឬស្ងួតនៅពេលដាំ។



**ជីករណ្តៅបួនជ្រុងជម្រៅជ្រៅជាងថើង ១ដងកន្លះ។ រណ្តៅមូលបង្ការឫសឈើមិនឲ្យចាក់ទៅដល់ដីជុំវិញបាន។**



**ដាក់ដីក្នុងរណ្តៅដើម្បីឲ្យដើមកូនឈើមានកម្ពស់ស្មើគ្នានឹងផ្ទៃដីនៅពេលបំពេញរណ្តៅហើយ។ អ្នកក៏អាចដាក់ជីកំប៉ុសឬដីខ្មៅមានជីជាតិ ពីរបីក្តាប់ដៃ ដើម្បីផ្តល់ការចាប់ផ្តើមដ៏ល្អ។ បន្ទាប់ពីដាំរួច ចូរស្រោចទឹកនៅលើដីជុំវិញកូនឈើឲ្យជោគ។**

### ការផ្សាំកូនឈើក្នុងកន្លែងពិបាក



ក្នុងកន្លែងស្ងួត ចូរធ្វើរណ្តៅរាក់ជុំវិញ
កូនឈើដើម្បីត្រងទឹក។




នៅលើចំណោតភ្នំ ចូរធ្វើផ្ទៃរាបស្មើ
សម្រាប់កូនឈើនីមួយៗ។



នៅលើដីជម្រាល ចូរពូនដីជាទម្រង់
អក្សរV ស្ថិតនៅពីក្រោមកូនឈើ
ដើម្បីត្រងទឹកភ្លៀង។

### ការថែទាំដើមឈើតូចៗ

ដើមឈើត្រូវការការពារពេញមួយឆ្នាំដំបូងនៃជីវិត។ មានគម្រោងដាំដើមឈើជាច្រើនបានទទួលបរាជ័យដោយសារតែគ្មាននរណាម្នាក់ថែទាំដើមឈើ។

ប្រសិនបើអាកាសធាតុក្តៅនិងស្ងួត ត្រូវស្រោចទឹកកូនឈើមួយថ្ងៃម្តងនៅពេលដំបូង បន្ទាប់មកស្រោចពីរឬបីថ្ងៃម្តង។ ពីរបីសប្តាហ៍បន្ទាប់មកឫសឈើគួរអាចស្វែងរកទឹកបាន។ ប៉ុន្តែបើអាកាសធាតុនៅតែក្តៅនិងស្ងួត ត្រូវស្រោចទឹកតាមដែលដើមឈើត្រូវការ។

កាត់ស្មៅរហូតទាល់តែដើមឈើដុះខ្ពស់ជាងស្មៅ។ ប្រសិនបើសត្វ ឬកុមារអាចធ្វើឲ្យដើមឈើតូចៗខូច ចូរព័ទ្ធរបងជុំវិញវា។

ប្រសិនបើដើមឈើមិនលូតលាស់ល្អ ឬស្លឹកឈើប្រែពណ៌ជាលឿង ឬមិនល្អ អ្នកអាចជួយរោយជីធម្មជាតិ(មើលទំព័រ287)ជារង្វង់ឲ្យបានគ្របដណ្តប់ឫសទាំងអស់របស់ដើមឈើ។



ធ្វើរបងការពារដើមឈើតូចៗ។

# ការកែប្រែផ្លូវទឹកនិងដីល្បាយខ្សាច់ឡើងវិញ

រុក្ខជាតិនិងដើមឈើដែលដុះនៅតាមមាត់ទន្លេ ឬខ្សែទឹក និងដុះលើ**ដីល្បាយខ្សាច់**( តំបន់ដែលមានដីសើមឬលិចទឹករាល់ឆ្នាំ ) មានសារសំខាន់ជាច្រើននៅក្នុងទីជម្រាល។ ពួកវាគ្រប់គ្រងជំនន់ សម្អាតទឹក ជួយធ្វើឲ្យទឹកហូរហៀរលើដីជ្រាបទៅក្នុងដី និងផ្តល់ជម្រកដល់សត្វនិងរុក្ខជាតិជាច្រើនប្រភេទ។



**ទន្លេនេះនឹងហូរយ៉ាងលឿន និងអាចធ្វើឲ្យមានសំណឹកដី និងជំនន់នៅខ្សែទឹកខាងក្រោម។**

ខ្សែទឹកនិងទន្លេនៅក្នុងក្រុង ភាគច្រើនត្រូវបានធ្វើឲ្យហូរជាខ្សែត្រង់ ដើម្បីបង្ការជំនន់និងងាយដល់ការងារសំណង់ក្នុងក្រុង។ ប៉ុន្តែកាលណាទន្លេកាន់តែត្រង់ ទឹកហូរកាន់តែលឿន។ នៅពេលទឹកហូរលឿន វាបណ្តាលឲ្យឆាប់សឹកបាតទន្លេនិងច្រាំង និងទំនងជានឹងបង្កជំនន់នៅតំបន់នៅក្រោមខ្សែទឹក។ ជំនន់នាំថ្មធំៗនិងកំណាត់ឈើទៅផ្នែកខាងក្រោមខ្សែទឹក ដូច្នេះសូម្បីតែក្នុងរដូវប្រាំងក៏អ្នកអាចស្មានថាតើទន្លេអាចនឹងមានជំនន់ឬក៏អត់ ដោយការក្រឡេកមើលទំហំថ្ម និងកំណាត់ឈើនៅបាតទន្លេ។ ប្រសិនបើទន្លេដែលរាក់និងហូរយឺតៗ មានថ្មធំៗនៅបាតទន្លេនារដូវប្រាំង នោះវាជាសញ្ញានៃជំនន់ដ៏គ្រោះថ្នាក់ដែលនឹងនាំថ្មធំៗទាំងនេះទៅផ្នែកខាងក្រោមខ្សែទឹកនៅរដូវវស្សា។



**ទន្លេនេះនឹងហូរយឺតជាង ដែលអនុញ្ញាតឲ្យទឹកជ្រាបចូលទៅក្នុងដី។**

# ការកែប្រែជីវិតរុក្ខជាតិឡើងវិញ

រុក្ខជាតិដែលដុះនៅតាមមាត់ទន្លេ ជួយបន្ថយល្បឿនទឹកហូរ, បំបែកផ្លូវទឹក, និងទាញទឹកភ្លៀងឲ្យជ្រាបទៅក្នុងដី, ព្រមទាំងទប់ដីមិនឲ្យដាច់។




**កន្លែងដែលសឹក :**
ទឹកភ្លៀងហូរនៅលើផ្ទៃដី
និងហូរនាំស្រទាប់ដី
ទៅចាក់ក្នុងខ្សែទឹក។

**កន្លែងដែលបានកែប្រែ :**
រុក្ខជាតិនិងដើមឈើ ជួយធ្វើឲ្យ
ទឹកភ្លៀងជ្រាបចូលទៅក្នុងដី ដូច្នេះ
វាមានទឹកនិងស្រទាប់ដីតិចតួចដែល
ហូរចាក់ទៅក្នុងទន្លេ។

វិធីមួយក្នុងការបញ្ឈប់សំណឹកដីនៅតាមដងទន្លេនិងខ្សែទឹក គឺការដាំដើមឈើនៅសងខាងទន្លេនិងខ្សែទឹកទាំងនោះ។ ជាធម្មតាការដាំដើមឈើដែលមានទទឹងប្រហែល២០ទៅ៥០ម៉ែត្រនៅសងខាងទន្លេ នឹងកាត់បន្ថយសំណឹកដី។

ដើមឈើដែលចូលចិត្តមានឫសសើម អាចលូតលាស់បានយ៉ាងងាយពីកំណាត់មែកឈើ។ ដាំកំណាត់មែកឈើ២ឬច្រើនជួរ បន្ទាប់មកពូនគុម្ពោធនឹងមែកឈើនៅចន្លោះជួរទាំងនេះ។ ធ្វើបែបនេះដើម្បីទប់ដីមិនឲ្យដាច់ និងបង្កើតលក្ខខណ្ឌសម្រាប់ឲ្យរុក្ខជាតិនិងសត្វដទៃទៀតត្រឡប់មកវិញ។

ដើមឈើ គុម្ពឈើ និងស្មៅ អាចចាប់ផ្ដើមលូតលាស់ដោយខ្លួនឯងនៅពេលផ្នែកសងខាងនៃទន្លេមានស្ថានភាពនឹង។ ប្រសិនបើវាមិនដុះទេ អ្នកអាចដាំវា។ ប្រសិនបើអាច គួរធ្វើរបងទប់ស្កាត់មិនឲ្យសត្វចូល និងការពារកុំឲ្យមនុស្សចូលទៅកាប់ឈើនៅទីនោះ រហូតទាល់តែដើមឈើលូតលាស់ពេញរូបរាង។



**ការអភិរក្សនិងការកែប្រែដីល្បាយខ្សាច់ គឺជាផ្នែកមួយដ៏សំខាន់នៃការការពារទីជម្រាល។**